សុន្ទរកថារបស់**លោក ហ៊ីហ្គជិ យ៉ូស៊ីហ៊ីរ៉ូ**
ភារៈធារីស្តីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចផ្នែកវប្បធម៌របស់ប្រទេសជប៉ុន

២៤ កុម្ភៈ ២០១៣

**សូមគោរព លោក ឡាច ច័ន្ទសុវណ្ណ ប្រធានខេមរៈសហព័ន្ធការ៉ាតេ-ដូ!**
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីរួមក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយថ្ងៃនេះ សម្រាប់គម្រោងសាងសង់ក្លឹបហ្វឹកហាត់សម្រាប់ក្បាច់គុនយុទ្ធសិល្ប៍ជប៉ុន។ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាពិសេសដោយពិធីនេះត្រូវបានប្រារព្ធធ្វើឡើងក្នុងឱកាសដ៏ពិសេសនៃការបង្ហាញក្បាច់ការ៉ាតេក្នុងមហោស្រពគីហ្សូណាជប៉ុន-កម្ពុជាដើម្បីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងនេះមានគោលដៅលើកស្ទួយវិស័យក្បាច់គុនយុទ្ធសិល្ប៍ជប៉ុននៅកម្ពុជាតាមរយៈការសាងសង់អគារថ្មីកម្ពស់ពីរជាន់ ក៏ដូចជាការបំពាក់សម្ភារៈបរិក្ខារដែលចាំបាច់សម្រាប់ការប្រកួតជាផ្លូវការនានា។ ថវិកាជំនួយសរុបសម្រាប់គម្រោងនេះមានចំនួន១២០,៧៨០ដុល្លាអាមេរិក។ យើងរំពឹងថា ក្លឹបថ្មីនេះនឹងក្លាយជាមូលដ្ឋានសំខាន់សម្រាប់ក្បាច់គុនយុទ្ធសិល្ប៍ជប៉ុនដែលនឹងទាក់ទាញអ្នកហ្វឹកហាត់ជនជាតិខ្មែរកាន់តែច្រើនឡើងៗ។

ក្បាច់គុនយុទ្ធសិល្ប៍ជប៉ុនមិនត្រឹមតែដើម្បីអភិវឌ្ឍន៍កម្លាំងកាយរបស់យើងតែប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបណ្តុះផ្នែកគំនិតស្មារតីផងដែរ ជាពិសេស គំនិតអភិវឌ្ឍន៍ខ្លួនឯង ការតស៊ូអំណត់ ការចេះដាក់ខ្លួន និងសុជីវធម៌សង្គមជាដើម។ ខ្ញុំជឿជាក់ថា ការបណ្តុះគំនិតស្មារតីមានសារៈសំខាន់ណាស់សម្រាប់យុវជនដែលជាអ្នកមានកាតព្វកិច្ចក្នុងការអភិវឌ្ឍន៍សង្គមកម្ពុជាទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

ចាប់តាំងពីឆ្នាំ១៩៩២មក រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តផ្តល់ការឧបត្ថម្ភគាំទ្រដល់វិស័យអប់រំនៅកម្ពុជាទាំងផ្នែកសម្ភារៈ និង បច្ចេកទេស។ ខ្ញុំសង្ឃឹមថា គម្រោងដែលត្រូវបានចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងថែទាំយ៉ាងត្រឹមត្រូវដោយដៃគូរបស់យើងគឺខេមរៈសហព័ន្ធការ៉ាតេ-ដូ ដើម្បីឲ្យគ្រូបង្វឹក និង អ្នកហ្វឹកហាត់កាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះ ហើយក្បាច់គុនយុទ្ធសិល្ប៍ជប៉ុន រួមជាមួយគំនិតអប់រំដ៏មានតំលៃដែលផ្សារភ្ជាប់ជាមួយគ្នានោះនឹងរីកចំរើនជាបន្តទៀតក្នុងប្រទេសកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!